**ស្ថានទូតជប៉ុន**

ថ្ងៃទី 26 ខែ កុម្ភៈ ឆ្នាំ 2001

# សេចក្តីប្រកាសព័ត៌មាន

បណ្តាអ្នកយកព័ត៌មានទាំងអស់ ត្រូវបានអញ្ជើញអោយចូលរួមដើម្បីយកព័ត៌មាន និង ថតរូបភាព

## ពិធីសម្ពោធមជ្ឈមណ្ឌលនិតិសម្បទាខេត្តក្រចេះ

ថ្ងៃទី 27 ខែ កុម្ភៈ ឆ្នាំ 2001 វេលាម៉ោង 07:30 នាទី ព្រឹក

នៅបរិវេណមន្ទីរពេទ្យខេត្តក្រចេះ

ពិធីនេះ គឺដើម្បីសម្ពោធមជ្ឈមណ្ឌលនិតិសម្បទាដែលទើបសាងសង់រួចស្ថិតនៅក្នុងបរិវេណមន្ទីរពេទ្យខេត្តក្រចេះ ។

ការសាងសង់មជ្ឈមណ្ឌលនិតិសម្បទានេះ ដែលរួមមានអាគាររោងជាងមួយបំពាក់ទៅដោយសំភារៈសំរាប់ធ្វើដៃ-ជើងសិប្បនិមិត្ត និង អាគារការិយាល័យមួយ ត្រូវបានកសាងឡើងដោយអង្គការអតីតយុទ្ធជនអន្តរជាតិ/កម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយ បច្ចុប្បន្នបំរើការនៅកម្ពុជាជួយដល់ជនពិការ ។ តាមរយៈកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាកាលពីថ្ងៃទី 28 ខែកុម្ភៈ ឆ្នាំ 2000 រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាចំនួន US$ 66,570 ដល់គំរោងការនេះតាមរយៈជំនួយឧបត្ថម្ភរបស់ជប៉ុនសំរាប់គំរោងការទ្រង់ទ្រាយតូច ដែលហៅជាភាសាជប៉ុនថា " គូសាណូនេ " ។ ជាលទ្ធផលនៃគំរោងការនេះ ជនពិការទាំងឡាយ រួមទាំងជនពិការដោយសារមីននៅតំបន់ភាគឥសាន្ត ដែលមានខេត្តក្រចេះ-ស្ទឹងត្រែង-រតនគីរី និង មណ្ឌលគីរី មានមជ្ឈមណ្ឌលនិតិសម្បទាជាអចិន្ត្រៃយ៍ទី 1 សំរាប់ផ្តល់ការព្យាបាលដោយលំហាត់កាយសម្បទា - ធ្វើដៃ-ជើងសិប្បនិមិត្ត និង ផ្តល់នូវការណែនាំដ៏ត្រឹមត្រូវ ដល់គេ ។

" គូសាណូនេ" គឺជាជំនួយឧបត្ថម្ភរបស់ជប៉ុនដើម្បីជួយដល់គំរោងការតូចៗរបស់អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និង ក្នុងស្រុកនានា និង របស់អាជ្ញាធរមូលដ្ឋាន ហើយក៏ជាសរសរទ្រូងមួយដ៏សំខាន់នៃជំនួយសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុនចំពោះកម្ពុជា ។ ចាប់តាំងពីឆ្នាំ 1992 មក ទឹកប្រាក់សរុបចំនួន US$ 8,859,693 ហើយដែលបានផ្តល់ដោយរដ្ឋាភិបាលជប៉ុនតាមរយៈជំនួយ " គូសាណូនេ " នេះដើម្បីឧបត្ថម្ភដល់គំរោងការចំនួន 172 ជួយដល់ការខិតខំប្រឹងប្រែងស្តារឡើងវិញ និង អភិវឌ្ឍន៍ ជនបទនៃព្រះរាជាណាចក្រកម្ពុជា ។

❖❖❖

ស្ថានទូតជប៉ុន លេខ 75 មហាវិថីព្រះនរោត្តម ទូរស័ព្ទ: 023.21.71.61/4 ហ្វាក់: 023.21.61.62

E-mail Address: eoic@bigpond.com.kh